


ប្រជុំកោះ៤០០០ ដែលគេហៅថា កោះស៊ីផាដូន គឺជាអតិសុខុមនៃជីវិតនៅក្នុងទន្លេមេគង្គ
Photo: International Rivers

# ទំនប់ដនសាហុង

## ការប្រឡែងលេងជាមួយសុវត្ថិភាពស្បៀងអាហារ និងរបរចិញ្ចឹមជីវិតនៅតំបន់ទន្លេមេគង្គ

**ទំ**នប់វារីអគ្គិសនីដនសាហុង ដែលជាទំនប់ទីពីរក្នុងចំណោមទំនប់វារីអគ្គិសនីចំនួន ១១ ដែលបានគ្រោងសាងសង់ជាបន្តបន្ទាប់
នៅទន្លេមេគង្គក្រោម នឹងធ្វើឲ្យត្រីផ្លាស់ប្តូរទីជម្រកដោយមិនអាចវិលមកវិញ នៅក្នុងអាងទន្លេមេគង្គក្រោមទាំងមូល ដែលអាច
នឹងបណ្តាលឲ្យមានការបំផ្លិចបំផ្លាញប្រព័ន្ធអេកូឡូស៊ីសម្បូរបែបរបស់ទន្លេនេះ និងជីវភាពរស់នៅ ព្រមទាំងសន្តិសុខស្បៀងអាហារ
របស់ប្រជាជនរាប់រយពាន់នាក់។ ទំនប់វារីអគ្គិសនីដនសាហុង ដែលស្ថិតនៅទន្លេស៊ីផានដូន ភាគខាងត្បូងប្រទេសឡាវ ដោយមាន
ចម្ងាយតិចជាងពីរគីឡូម៉ែត្រពីព្រំដែនប្រទេសកម្ពុជានោះ គំរាមកំហែងដល់អតិសុខុមដែលគ្មានពីរនៃទន្លេមេគង្គ ដែលអាចជួយទ្រ
ទ្រង់ជីវិតតាមអាងទន្លេមេគង្គក្រោមទាំងមូល។

ទន្លេស៊ីផានដូន ជាផ្នែកមួយនៃទន្លេមេគង្គដ៏ស្រស់ស្អាតនិងទាក់ទាញ ដែលកកើតឡើង
ដោយទន្លេបត់បែនយ៉ាងស្មុគ្រស្មាញជាច្រើននៅជុំវិញប្រជុំកោះ និងដៃសមុទ្រ។
ទន្លេនេះមានឈ្មោះល្បីល្បាញខាងជីវចំរុះក្នុងទឹក និងត្រីយ៉ាងសម្បូរបែបរបស់វា។
ក្រុមអ្នកវិទ្យាសាស្ត្របានរកឃើញនិងចាត់ទុកតំបន់នេះថាមានច្រកផ្លូវយ៉ាងសំខាន់ស
ម្រាប់ឲ្យត្រីធ្វើចរាចរណ៍នៅទូទាំងអាងទន្លេមេគង្គក្រោម។ ទំនប់ដនសាហុង ដែលមាន
ទីតាំងកាត់តាមទន្លេហ៊ូសាហុង – ជាទន្លេធំនៅក្នុងតំបន់ដែលអនុញ្ញាតឱ្យត្រីហែលពេ
ញមួយឆ្នាំ ទាំងនៅខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោមនោះ បង្កឲ្យមានហានិភ័យខ្លាំ
ងចំពោះផ្លូវត្រីហែលនៅក្នុងតំបន់ទាំងមូល, ដោយមានការគំរាមកំហែងដល់ការប្រេក
បរបរចិញ្ចឹមជីវិត និងការនេសាទត្រីបែបពាណិជ្ជកម្មរបស់អ្នកស្រុកនៅក្នុងប្រទេសឡាវ
និងនៅទន្លេមេគង្គទាំងមូល។

តាមការសិក្សាមួយដែលបានធ្វើឡើងដោយគណៈកម្មការទន្លេមេគង្គ (MRC)
កាលពីឆ្នាំ ១៩៩៤ បានបញ្ជាក់ថា ទន្លេស៊ីផានដូន មាន "លក្ខណៈធម្មជាតិកម្រណាស់
ដូច្នេះគេត្រូវខិតខំថែរក្សាវាឲ្យបានគង់វង្ស ពីគម្រោងអភិវឌ្ឍន៍"។

ដោយទទួលស្គាល់អំពីតម្លៃជីវចម្រុះជាសកលនៃជម្រកសត្វនៅលើដីកោះ – ក្នុងទន្លេគ្មា
នពីររបស់ទន្លេស៊ីផានដន រដ្ឋាភិបាលនៃប្រទេសឡាវ កន្លងមកបានពិចារណាស្នើដាក់តំ
បន់នោះជាតំបន់ដីសើម តាមសន្ធិសញ្ញារ៉ាំសា (Ramsar)។ មិនឆ្ងាយប៉ុន្មាននៅខ្សែទឹកខា
ងក្រោម គ្រាន់តែឆ្លងព្រំដែនប្រទេសកម្ពុជា គឺជាតំបន់ដីសើមស្ទឹងត្រែង ជាតំបន់ដែលបា
នកំណត់តាមសន្ធិសញ្ញារ៉ាំសា តាំងពីឆ្នាំ ១៩៩៩។

ទោះបីជា វាស្ថិតនៅជិតនឹងប្រទេសកម្ពុជាក៏ដោយ ក៏គេពុំឃើញមានការវាយតម្លៃផលប៉ះ
ពាល់ឆ្លងដែនសម្រាប់គម្រោងនេះឡើយ រីឯវិធានការដែលបានស្នើឡើងដើម្បីកាត់បន្
យផលប៉ះពាល់ដោយសារទំនប់វារីអគ្គិសនីនេះ ជាពិសេសផលប៉ះពាល់ដល់ផ្លូវត្រីធ្វើ
ចរាចរណ៍ ក៏ពុំទាន់បង្ហាញឲ្យឃើញលទ្ធផលជាផ្លែផ្កា នៅតំបន់ទន្លេមេគង្គនៅឡើយ។
ដោយការអនុវត្តដូចគ្នានឹងគម្រោងទំនប់វារីអគ្គិសនី សាយ៉ាបុរីដ៏ចម្រូងចម្រាសកន្លងមក
គម្រោងទំនប់វារីអគ្គិសនីដនសាហុង បានធ្វើឲ្យមានការព្រួយបារម្ភយ៉ាងខ្លាំង
ពីរដ្ឋាភិបាលប្រទេសជិតខាង ព្រមទាំងបណ្តាសហគមន៍ ក្រុមអ្នកវិទ្យាសាស្ត្រ
និងសង្គមស៊ីវិលក្នុងតំបន់ និងអន្តរជាតិ។ គម្រោងនេះបានប្រឈមនឹងដំណើរការពិគ្រោះ
យោបល់ថ្នាក់តំបន់មិនដាច់ស្រេច តាមនីតិវិធីស្តីពីការជូនដំណឹង និងការពិគ្រោះយោបល់
និងការព្រមព្រៀងជាមុន របស់គណកម្មការទន្លេមេគង្គ ហើយអនាគតនៃគម្រោងនេះនៅ
មិនទាន់ច្បាស់លាស់នៅឡើយ។




Map of Don Sahong Dam

## ទំនប់ដនសាហុង

មានការរំពឹងថា ទំនប់ដនសាហុង ដែលមានកម្ពស់ ២៥ ម៉ែត្រនេះ នឹងផលិតបានអគ្គិសនីកម្លាំង ២៦០ មេហ្គាវ៉ាត់សម្រាប់ប្រើប្រាស់ក្នុងប្រទេស និងសម្រាប់នាំចេញទៅប្រទេសកម្ពុជា ឬប្រទេសថៃ។ ក្រុមហ៊ុនអភិវឌ្ឍគម្រោង គឺក្រុមហ៊ុនថាមពលដនសាហុង (Don Sahong Power) ជាក្រុមហ៊ុនវិនិយោគរួមទុនរវាងក្រុមហ៊ុនសាជីវកម្ម Mega First Corporation Berhad (MFCB) ដែលជាក្រុមហ៊ុនរបស់ប្រទេសម៉ាឡេស៊ី និងរដ្ឋាភិបាលនៃប្រទេសឡាវ។ កាលពីខែមីនា ឆ្នាំ ២០០៦ ក្រុមហ៊ុនម៉ាឡេស៊ី MFCB បានចុះហត្ថលេខាលើអនុស្សរណៈនៃការយល់ជាមួយរដ្ឋាភិបាលឡាវ ដើម្បីរៀបចំការសិក្សាអំពីលទ្ធភាពសម្រាប់គម្រោងនេះ។ រហូតដល់ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០១៣ រដ្ឋាភិបាលឡាវពុំបានជូនដំណឹងអំពីគោលបំណងរបស់ខ្លួនក្នុងការសាងសង់ទំនប់ដនសាហុងទៅគណៈកម្មការទន្លេមេគង្គ និងបណ្តាប្រទេសដែលជាសមាជិកនៃគណៈកម្មការនេះទេ ដូចជាប្រទេសកម្ពុជា ថៃ និងប្រទេសវៀតណាមជាដើម។ ក្រោយពីមានការព្រួយបារម្ភយ៉ាងខ្លាំងពីរដ្ឋាភិបាលប្រទេសជិតខាង កាលពីខែមិថុនា ឆ្នាំ ២០១៤ រដ្ឋាភិបាលនៃប្រទេសឡាវបានយល់ព្រមដាក់គម្រោងនេះដើម្បីស្នើសុំការពិគ្រោះយោបល់ជាមុនទៅតាមលក្ខខណ្ឌតម្រូវនៃកិច្ចព្រមព្រៀងទន្លេមេគង្គ ឆ្នាំ ១៩៩៥។



ក្មេងប្រុសម្នាក់លើកត្រីដែលចាប់បានកាន់ដោយមោទនភាព, ខ្សែទឹកខាងលើនៃការដ្ឋានទំនប់ដនសាហុង
Photo: International Rivers

នៅថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០១៥ ក្រុមហ៊ុនថាមពលដនសាហុង (Don Sahong Power) បានឈានដល់ការចុះកិច្ចព្រមព្រៀងសម្បទានមួយជាមួយរដ្ឋាភិបាលនៃប្រទេសឡាវ ដើម្បីសាងសង់ ដំណើរការ និងផ្ទេរគម្រោងនេះក្នុងរយៈពេល២៥ ឆ្នាំ។ ក្រោយពីការប្រកាសនេះ នៅថ្ងៃទី ១ ខែតុលាឆ្នាំ ២០១៥ ក្រុមហ៊ុន Mega First Corporation Berhad បានប្រកាសថា កិច្ចព្រមព្រៀងទិញថាមពលពីទំនប់វារីអគ្គិសនីដនសាហុង ត្រូវបានចុះហត្ថលេខា ជាមួយសហគ្រាសអគ្គិសនីរដ្ឋនៃប្រទេសឡាវ។ ក្រុមហ៊ុនសាជីវកម្ម Sinohydro អន្តរជាតិរបស់ប្រទេសចិន ត្រូវបានចុះកិច្ចសន្យាសាងសង់ទំនប់នៃគម្រោងនេះ។

## ផលផល & សុវត្ថិភាពស្បៀងអាហារស្ថិតក្នុងហានិភ័យ

ផលប៉ះពាល់ផ្នែកបរិស្ថាននិងសេដ្ឋកិច្ចសង្គមគួរឲ្យចាប់អារម្មណ៍បំផុតដោយសារទំនប់វារីអគ្គិសនីដនសាហុងគឺ ផលប៉ះពាល់ទៅលើជលផលត្រីក្នុងស្រុក និងក្នុងតំបន់។ ទន្លេហ៊ូសាហុង (Hou Sahong) គឺជាទន្លេ និងជាច្រកចេញចូលធំបំផុតនៅក្នុងតំបន់ស៊ីផានដូន ដែលអនុញ្ញាតឱ្យត្រីហែលបានពេញមួយឆ្នាំ។ ពូជត្រីច្រើនជាង ១០០ ប្រភេទត្រូវបានគេរាយការណ៍ថាធ្វើចរាចរណ៍តាមទន្លេហ៊ូសាហុង។ ភាគច្រើននៃប្រភេទត្រីទាំងនេះ ត្រូវបានគេចាត់ថ្នាក់ជា ត្រីដែលមានកម្រិត "ហែលផ្លាស់ទីកម្រិតខ្ពស់" ដោយតាមឯកសារខ្លះថា ហែលឆ្ងាយតាំងពីដីសណ្តទន្លេមេគង្គ ប្រទេសវៀតណាម។ ការសង់ទំនប់បិទទន្លេហ៊ូសាហុង ជាការគំរាមកំហែងដល់ការហែលឆ្លងកាត់ ការរកចំណី និងការបង្កើតកូនរបស់ត្រីចម្រុះច្រើនប្រភេទទាំងនេះ។

ផលវិបាកនៃការបាត់បង់ផ្លូវធ្វើចរាចរណ៍របស់ត្រី អាចនឹងបណ្តាលឲ្យមានផលប៉ះពាល់ខ្លាំងលើសន្តិសុខស្បៀងនៅក្នុងតំបន់។ ផលនេសាទត្រីគឺជាផ្នែកយ៉ាងសំខាន់នៃរបបអាហារនិងការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាសហគមន៍នៅតាមទន្លេមេគង្គ។ ប្រូតេអ៊ីនសាច់សត្វនៅក្នុងតំបន់ពី ៤០ ទៅ ៧០% បានមកពីត្រី។ តាមការសិក្សាបានបង្ហាញថា អាចកើនឡើងរហូតដល់ ៨០% សម្រាប់ប្រជាសហគមន៍ដែលរស់នៅផ្នែកខាងលើ និងខាងក្រោមល្បាក់ខោន។ យោងតាមការសិក្សាស្រាវជ្រាវដោយសាកលវិទ្យាល័យជាតិអូស្ត្រាលី បង្ហាញថា វាមានការលំបាកយ៉ាងខ្លាំងក្នុងការជំនួសប្រូតេអ៊ីន និងកាឡូរី ពីត្រីតំបន់ទន្លេមេគង្គ និងតម្រូវឱ្យមានកា

## មើលមួយត្រួសៈ ក្រុមហ៊ុនសំខាន់ៗដែលពាក់ព័ន្ធនឹងទំនប់ដនសាហុង

**ក្រុមហ៊ុន Mega First Corporation Berhad (MFCB):** ជាក្រុមហ៊ុនអភិវឌ្ឍគម្រោង ដែលបានចុះហត្ថ លេខា បណ្ដាក់ទុនរួមគ្នាជាមួយរដ្ឋាភិបាលឡាវដើម្បីបង្កើតក្រុមហ៊ុនថាមពលដនសាហុង (Don Sahong Power Company)។

**AECOM** – ត្រូវបានតែងតាំងដោយ ក្រុមហ៊ុនសាជីវកម្ម MFCB នៅដើមឆ្នាំ ២០០៨ ជាវិស្វកររបស់ម្ចាស់ក្រុមហ៊ុន ដើម្បីបំពេញការសិក្សាអំពីលទ្ធភាពនិងជួយដល់ MFCB ក្នុងការជាវថាមពល និងកិច្ចព្រមព្រៀងសម្បទាន។ នៅខែឧសភា ឆ្នាំ ២០១០ កិច្ចសន្យាស្ដីពីការផ្ដល់សេវាកម្មរបស់ AECOM ត្រូវបានបន្ត។

**ក្រុមហ៊ុនពិគ្រោះយោបល់ថ្នាក់ជាតិរបស់ប្រទេសឡាវ (National Consulting Company of Laos)** – បានរៀបចំឯកសារគម្រោងឆ្នាំ ២០១៣ មានដូចជា របាយការណ៍វាយតម្លៃស្ដីពីផលប៉ះពាល់បរិស្ថាន។

**ក្រុមហ៊ុន Sinohydro International Corporation** – លទ្ធកម្មវិស្វកម្ម និងកិច្ចសន្យាសាងសង់។

**Pöyry** – ត្រូវជួលដោយ MFCB នៅឆ្នាំ ២០១២ ឲ្យពិនិត្យឡើងវិញលើគ្រប់ទិដ្ឋភាពនៃគម្រោងទំនប់វារីអគ្គិសនីដនសាហុង។

**Fisktek** – ដំបូងបានទទួលការងារពិនិត្យឡើងវិញលើការរៀបចំប្លង់ដែលមានស្រាប់សម្រាប់វិធានការកាត់បន្ថយផលប៉ះពាល់ច្រកចរាចរណ៍របស់ត្រី និងផ្ដល់សំណើសម្រាប់ការកែតម្រូវតាមទន្លេធម្មជាតិ ដែលក្រោយមក Fishtek បានបំពេញការងារកាន់តែពេញលេញថែមទៀត ជាអ្នករចនាប្លង់កែលម្អច្រកត្រីចរាចរណ៍នៅខ្សែទឹកខាងលើ។

រកើនឡើងនូវធនធានដី និងទឹកឲ្យបានច្រើន ជាពិសេសនៅក្នុងប្រទេសកម្ពុជា។ ម្យ៉ាងទៀត ការថយចុះបរិមាណនៃការផ្គត់ផ្គង់ត្រី អាចនឹងបណ្ដាលឲ្យត្រីឡើងថ្លៃនៅតាមទីផ្សារ ដែលមានន័យថា បណ្ដាសហគមន៍ដែលក្រីក្រ នឹងត្រូវចំណាយលុយកាន់តែច្រើនសម្រាប់ទិញត្រីមកធ្វើជាម្ហូប។

គេមិនអាចកំណត់បរិមាណនៃកម្រិតបាត់បង់ជលផលត្រីពីការបាត់បង់ទន្លេហូសាហុង តាមរយៈឯកសារសិក្សាដែលមានស្រាប់ឡើយ ដោយសារពុំមានទិន្នន័យជាមូលដ្ឋានគ្រប់គ្រាន់អំពីប្រភេទត្រីដែលធ្វើដំណើរកាត់តាមតំបន់ទន្លេមេគង្គ ក៏ដូចជាបណ្ដាទន្លេ និងលក្ខខណ្ឌនានាដែលវាត្រូវការសម្រាប់ហែលដែរ។ លើសពីនេះទៅទៀត ការសិក្សាដែលចេញផ្សាយដោយក្រុមហ៊ុនអភិវឌ្ឍន៍នោះ នៅមិនទាន់បានពិចារណាអំពីផលប៉ះពាល់ឆ្លងដែនដោយសារគម្រោងនេះទេ ទាំងផលប៉ះពាល់ដល់បណ្ដាសហគមន៍រស់នៅផ្នែកខ្សែទឹកខាងក្រោម និងប្រព័ន្ធអេកូឡូស៊ីនៅក្នុងប្រទេសកម្ពុជានិងវៀតណាម និងបណ្ដាសហគមន៍រស់នៅផ្នែកខ្សែទឹកខាងលើនៅប្រទេសថៃ។

### មូលដ្ឋានសាកល្បងសម្រាប់វិធានការកាត់បន្ថយផលប៉ះពាល់គ្មានការអះអាងបញ្ជាក់ និងមិនប្រាកដប្រជា

ទំនប់វារីអគ្គិសនីដនសាហុងគឺអាស្រ័យលើវិធានការនានាដែលបានស្នើឡើង ដើម្បីកាត់បន្ថយផលប៉ះពាល់ការបាត់បង់សម្រាប់ការធ្វើដំណើរផ្លាស់ទីរបស់ត្រី ដោយទន្លេ ហូសាហុង។ ក្រុមហ៊ុនអភិវឌ្ឍន៍ស្នើសុំរៀបចំរចនាសម្ព័ន្ធវិស្វកម្មទន្លេជិតល្បាក់ខោននោះឡើងវិញ គឺទន្លេ Hou Xang Phuek និង ទន្លេ Hou Sadam ដោយពង្រីកនិងជីកទន្លេនេះឲ្យកាន់តែធំនិងជ្រៅជាងមុន ធ្វើឲ្យដូចលក្ខណៈរបស់ទន្លេហូសាហុង និងបង្កើតច្រកផ្លូវសម្រាប់ត្រីហែល។ ប៉ុន្តែ វិធានការបែបនេះមិនបានបង្ហាញថា ធ្វើទៅបានឡើយនៅទន្លេមេគង្គ។ ការពិនិត្យឡើងវិញផ្នែកបច្ចេកទេសលើគម្រោងដោយគណៈកម្មការទន្លេមេគង្គ បានកត់សម្គាល់ថា នៅក្នុងឯកសារគម្រោងមានផ្ដល់ព័ត៌មានលម្អិតអំពីវិធានការទាំងនេះតិចតួចណាស់។ ម្យ៉ាងទៀត ប្រសិនបើ វិធានការទាំងនេះមិនទទួលបានជោគជ័យទេ គេមិនដឹងច្បាស់ថា អ្នកណាទទួលខុសត្រូវ ឬថា តើផលប៉ះពាល់ទាំងនេះនឹងត្រូវផ្ដល់សំណងយ៉ាងណា។

សន្មតថា លក្ខខណ្ឌតម្រូវសម្រាប់កម្រិតនៃទឹកហូរមកពីទន្លេមេគង្គដែលត្រូវការនោះ ហូរកាត់ទន្លេហូសាហុង ដើម្បីទ្រទ្រង់ដំណើរការទំនប់វារីអគ្គិសនីនេះ



លី ឧបករណ៍ចាប់ត្រីបូរាណ នៅទន្លេស៊ីផានដូន, នៅក្បែរការដ្ឋានទំនប់ដនសាហុង

Photo: International Rivers

ទៅចុះ អ៊ីចឹងនៅតែមិនច្បាស់ថា តើគេអាចរក្សាទឹកហូរឲ្យគ្រប់គ្រាន់ពេញមួយឆ្នាំនៅក្នុងទន្លេដែលជាជម្រើសជំនួសដើម្បីឲ្យមានការទាក់ទាញត្រីផង និងធ្វើជាផ្លូវត្រីហែលផងយ៉ាងម៉េច។ កាលណាគេត្រូវការទឹកកាន់តែច្រើនដើម្បីធានាប្រសិទ្ធភាពផ្លូវត្រីហែលនៅផ្នែកខាងលើទន្លេ ពេលនោះវានឹងមានទឹកកាន់តែតិចសម្រាប់ផលិតកម្មវារីអគ្គិសនី។ ដោយគ្មានទិន្នន័យជាមូលដ្ឋាន ឬវិធានការត្រឹមត្រូវសម្រាប់ការត្រួតពិនិត្យជាប្រចាំ ដូច្នេះវាត្រូវប្រឈមការលំបាកក្នុងការស្វែងយល់ថា តើបញ្ហាដែលកើតចេញពីការអនុវត្តគម្រោង និងវិធីសាស្ត្រដោះស្រាយកំហុសបច្ចេកទេសនឹងត្រូវដោះស្រាយដោយរបៀបណា។

បន្ទុកនៃការទទួលខុសត្រូវគឺស្ថិតនៅលើក្រុមហ៊ុនអភិវឌ្ឍគម្រោងដែលត្រូវពន្យល់ និងបង្ហាញអំពីប្រសិទ្ធផលពីការបង្កើតគម្រោងទំនប់នេះ និងពីវិធានការកាត់បន្ថយផលប៉ះពាល់ មុនពេលចាប់ផ្ដើមសាងសង់។ ទោះជាយ៉ាងនេះក្ដី កិច្ចព្រមព្រៀងគម្រោង បានដំណើរការទៅមុខដោយគ្មានមូលដ្ឋានភស្តុតាងវិទ្យាសាស្ត្រ ដែលមានន័យថា ភាពមិនច្បាស់លាស់ជាច្រើននៅតែបណ្ដាលឲ្យជលផលទន្លេមេគង្គស្ថិតក្នុងហានិភ័យ។

### ផ្សោតទឹកសាបអ៊ីរ៉ាវ៉ាឌីរដែលជិតផុតពូជស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ខ្លាំង

ទំនប់វារីអគ្គិសនីដនសាហុង មានទីតាំងស្ថិតនៅមួយគីឡូម៉ែត្រខាងលើទីជម្រកយ៉ាងសំខាន់សម្រាប់ផ្សោតទឹកសាបអ៊ីរ៉ាវ៉ាឌីប្រាំមួយក្បាលដែលរស់នៅក្នុងអាងទឹកជ្រៅឆ្លងដែនរវាងប្រទេសឡាវនិងប្រទេសកម្ពុជា។ អាងត្រីផ្សោតអ៊ីរ៉ាវ៉ាឌីគឺជាកន្លែងមួយក្នុងចំណោមកន្លែងសំខាន់ៗដែលទាក់ទាញទេសចរនៅក្នុងតំបន់ និងជាប្រភពប្រាក់ចំណូលយ៉ាងសំខាន់សម្រាប់បណ្ដាសហគមន៍ដែលរស់នៅខ្សែទឹកខាងក្រោមក្នុងប្រទេសកម្ពុជា។ ចំនួនត្រីផ្សោតអ៊ីរ៉ាវ៉ាឌីក្នុងទន្លេមេគង្គប្រឈមការបាត់បង់ផុតពូជយ៉ាងធ្ងន់ធ្ងរ ហើយមានចំនួននៅសល់តិចជាង៨៥ក្បាលដែលភាគច្រើននៃផ្សោតទាំងនោះត្រូវបានគេឃើញរស់នៅផ្នែកខ្សែទឹកខាងក្រោមនៃទន្លេនៅក្នុងប្រទេសកម្ពុជា។ ដោយការដ្ឋានទំនប់នេះស្ថិតនៅជិតអាងត្រីផ្សោត ដូច្នេះការសាងសង់ និងប្រតិបត្តិការរបស់គម្រោង អាចបង្កើនហានិភ័យខ្លាំងដល់ត្រីផ្សោតដ៏តិចតួចនិងប្រឈមការបាត់បង់ជិតផុតពូជនេះ ដោយសារសំឡេងកើនឡើងខ្លាំង និងបណ្ដាលមកពីសកម្មភាពជុំវិញការដ្ឋានទំនប់វារីអគ្គិសនីនេះ ក៏ដូចជាមានហានិភ័យបណ្ដាលមកពីការជីកកកាយថ្មស្ងួតបាតទន្លេហូសាហុងនៅខ្សែទឹកខាងលើនោះដែរ។ ផលប៉ះពាល់ដែលគេរំពឹងថានឹងកើតមានចំពោះការហែលផ្លាស់ទីរបស់ត្រី ក៏នឹងមានផលប៉ះពាល់ដល់ការផ្ដល់ស្បៀងអាហារ និងការចិញ្ចឹមជីវិតសម្រាប់ត្រីផ្សោតដែរ។ ប្រសិនបើត្រីផ្សោតនៅក្នុងអាងនេះត្រូវបាត់បង់ វាអាចនឹងបន្ថែមផលប៉ះពាល់ទៅលើការថយចុះពូជត្រីផ្សោតអ៊ីរ៉ាវ៉ាឌីនៅទន្លេមេគង្គ។ ការថយចុះយ៉ាងច្រើននៃចំនួនត្រីដ៏តិចតួចបែបនេះ នឹងបង្កើនហានិភ័យយ៉ាងខ្លាំងចំពោះការបាត់បង់ផុតពូជប្រភេទត្រីផ្សោត។

### ដំណើរការពិគ្រោះយោបល់ថ្នាក់តំបន់មិនដាច់ស្រេច

កាលពីខែកញ្ញា ឆ្នាំ ២០១៣ ប្រទេសឡាវបានជូនដំណឹងជាផ្លូវការទៅគណៈកម្មការទន្លេមេគង្គ និងប្រទេសជាសមាជិក អំពីគោលបំណងរបស់ខ្លួនក្នុងការសាងសង់ទំនប់វារីអគ្គិសនីដនសាហុង។ ឆ្លើយតបទៅនឹងការព្រួយបារម្ភអំពីផលប៉ះពាល់ឆ្លងដែនដោយសារគម្រោងដែលលើកឡើងដោយបណ្ដាប្រទេសជិតខាង រដ្ឋាភិបាលឡាវបានយល់ព្រមដាក់ស្នើសុំការពិគ្រោះយោបល់ថ្នាក់តំបន់អំពីគម្រោងទំនប់វារីអគ្គិសនីដនសាហុង ទៅតាមនីតិវិធីស្ដីពីការជូនដំណឹង ការពិគ្រោះយោបល់ និងការយល់ព្រមជាមុន (PNPCA) របស់គណៈកម្មការទន្លេមេគង្គ។

INTERNATIONAL RIVERS
people • water • life




"ទន្លេមេគង្គមិនសម្រាប់លក់ទេ", បណ្តាសហគមន៍ថៃតវ៉ាប្រឆាំងនឹងគម្រោងទំនប់វារីអគ្គិសនីនានានៅតាមដងទន្លេមេគង្គក្រោមជាផ្នែកមួយនៃទិវាអន្តរជាតិ ឆ្នាំ ២០១៥ សកម្មភាពការពារទន្លេ។ Photo: International Rivers

ទោះជាយ៉ាងនេះក្តី ក៏គេមើលឃើញជាទូទៅថា ដំណើរការនោះជាវិធីមួយសម្រាប់រដ្ឋាភិបាលនៃប្រទេសឡាវ ដើម្បីធ្វើឲ្យសកម្មភាពរបស់ខ្លួនស្របច្បាប់ ទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ ឆ្នាំ ១៩៩៥ តែប៉ុណ្ណោះ។ កាលបរិច្ឆេទចាប់ផ្តើមជាផ្លូវការសម្រាប់ដំណើរការពិគ្រោះយោបល់ជាមុនបានកំណត់យក ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៤។ ប៉ុន្តែ គណៈកម្មការទន្លេមេគង្គពុំបានប្រកាសទេ រហូតដល់ថ្ងៃទី២ ខែតុលា ឆ្នាំ ២០១៤ គឺចូលជិតបីខែក្នុងដំណើរការរយៈពេលប្រាំមួយខែ។ ការពិគ្រោះយោបល់ជាមុននេះ បានប្រព្រឹត្តទៅដោយគ្មានព័ត៌មានមូលដ្ឋានគ្រប់គ្រាន់ និងដោយគ្មានរបាយការណ៍វាយតម្លៃស្តីពីផលប៉ះពាល់ឆ្លងដែនឡើយ ដែលមានន័យថា ប្រទេសជិតខាង មានលទ្ធភាពផ្ទាល់ខ្លួនក្នុងការវាយតម្លៃផលប៉ះពាល់ជាក់ស្តែងដែលបណ្តាលមកពីគម្រោងពាក់ព័ន្ធនឹងការប្រើប្រាស់ទន្លេ តិចតួចណាស់។ ម្យ៉ាងទៀត នៅមានការព្រួយបារម្ភជាច្រើនអំពីបញ្ហានៃការអនុវត្តដំណើរការនៃការជូនដំណឹង ការពិគ្រោះយោបល់ និងការព្រមព្រៀងជាមុន (PNPCA) នៃគម្រោងទំនប់សាយ៉ាបុរី ដែលលើកឡើងដោយគណៈកម្មការទន្លេមេគង្គ និងរដ្ឋាភិបាលម្ចាស់ជំនួយ ហើយបញ្ហាដែលមិនត្រូវបានដោះស្រាយ ឬត្រូវដោះស្រាយមុនដំណើរការ បានចាប់ផ្តើមកើតឡើងដដែលចំពោះគម្រោងទំនប់ដនសាហុង។

នៅថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០១៥ គណៈកម្មាធិការចំរុះនៃគណៈកម្មការទន្លេមេគង្គ បានជួបប្រជុំ នៅថ្ងៃបញ្ចប់ដំណើរការពិគ្រោះយោបល់ជាមុនរយៈពេលប្រាំមួយខែដំបូងនៃគម្រោងទំនប់ដនសាហុង។ នៅពេលប្រជុំនោះ ប្រទេសថៃ កម្ពុជា និងវៀតណាមបានអំពាវនាវរៀងៗខ្លួន សុំឱ្យមានការពន្យារពេលនៃដំណើរការពិគ្រោះយោបល់ជាមុននេះ ដោយបានស្នើសុំឲ្យមានការសិក្សាជាមូលដ្ឋានបន្ថែមទៀត និងមានការវាយតម្លៃផលប៉ះពាល់ឆ្លងដែនល្អិតល្អន់ជាងនេះ។ ទោះជាយ៉ាងនេះក្តី ក៏រដ្ឋាភិបាលនៃប្រទេសឡាវបានទទូចថា ដំណើរការពិគ្រោះយោបល់ជាមុនត្រូវបញ្ចប់។ ដោយសារតែប្រទេសទាំងបួនមិនឯកភាព ទើបមានការសម្រេចចិត្តអន្តររដ្ឋាភិបាល ឲ្យមានការពិភាក្សាថ្នាក់រដ្ឋមន្ត្រីវិញ។ នៅខែមិថុនា ឆ្នាំ ២០១៥ គណៈកម្មការទន្លេមេគង្គបានចេញសេចក្តីថ្លែងការណ៍ បញ្ជាក់ថា ក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គមិនអាចឈានដល់ការសម្រេចកិច្ចព្រមព្រៀង ទាក់ទងនឹងដំណើរការពិគ្រោះយោបល់ជាមុន សម្រាប់គម្រោងទំនប់ដនសាហុងទេ ដូច្នេះហើយដោយសារតែនៅមានការខ្វែងគំនិតគ្នា ដូច្នេះការពិភាក្សាត្រូវលើកទៅថ្នាក់រដ្ឋាភិបាលវិញ ដើម្បីរកដំណោះស្រាយតាមរយៈការទូត។ ការព្រួយបារម្ភចំពោះគម្រោងនេះ និងតម្រូវការសិក្សាបន្ថែមទៀតត្រូវបានលើកឡើងជាថ្មីទៀត ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

## ប្រវត្តិវែងឆ្ងាយពាក់ព័ន្ធការបារម្ភថ្នាក់តំបន់

ចាប់តាំងពីបានចុះហត្ថលេខាដំបូងលើអនុស្សរណៈយោគយល់គ្នានៅឆ្នាំ ២០០៦ ស្តីពីគម្រោងទំនប់ វារីអគ្គិសនីដនសាហុងនោះមក មានការជំទាស់យ៉ាងខ្លាំងពីក្រុមអ្នកវិទ្យាសាស្ត្រ អ្នកជំនាញទន្លេមេគង្គ បណ្តាសហគមន៍តាមដងទន្លេ អង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលតំបន់ទន្លេមេគង្គ ចំពោះគម្រោងដែលបានស្នើសុំនេះ ដោយសារតែផលប៉ះពាល់ឆ្លងដែនរបស់គម្រោង និងផលប៉ះពាល់ដល់សន្តិសុខស្បៀងនៅក្នុងតំបន់។ រដ្ឋាភិបាលប្រទេសកម្ពុជា ថៃ និងវៀតណាមបានអំពាវនាវឱ្យមានការវាយតម្លៃបន្ថែមទៀតអំពីផលប៉ះពាល់ឆ្លងដែនដោយសារគម្រោងនេះ។ ទាំងប្រទេសកម្ពុជា និងប្រទេសថៃក៏បានអំពាវនាវដែរថា រាល់ការសម្រេចចិត្តទាំងអស់ដែលទាក់ទងនឹងទំនប់ទន្លេមេគង្គត្រូវផ្អាករហូតដល់បញ្ចប់ការសិក្សាពីរ ដែលកំពុងដំណើរការដើម្បីវាយតម្លៃអំពីផលប៉ះពាល់បណ្តាលមកពីគម្រោងទំនប់វារីអគ្គិសនី ទៅលើទន្លេមេគង្គក្រោមគឺៈ សិក្សាក្រុមប្រឹក្សាគណកម្មការទន្លេមេគង្គ និងការសិក្សាដីសណ្តទន្លេមេគង្គ។

## គម្រោងបង្វែរទិសទឹកថាកូ (Thako)

គម្រោងបង្វែរទិសទឹក Thako ដែលមានកម្លាំង ១៧២ មេហ្គាវ៉ាត់ត្រូវបានស្នើសុំជាជម្រើសមួយជំនួស ទំនប់វារីអគ្គិសនីដនសាហុង។ ដោយស្ថិតនៅខាងកើតល្បាក់ខោន គម្រោងនេះ ពុំមានសង់របាំងកាត់ទន្លេនេះទេ ប៉ុន្តែវានឹងបង្វែរទិសទឹកតាមបរិមាណចង់បានដោយព្រែកជីកនៅជុំវិញល្បាក់ខោនផាផេង (Khone Phapheng)។ បើប្រៀបធៀបនឹងរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថានសម្រាប់គម្រោងពីរនេះ គម្រោងថាកូ មានហានិភ័យចំពោះជីវចំរុះ និងប្រព័ន្ធអេកូឡូស៊ីនៃទន្លេមេគង្គតិចច្រើនជាងទំនប់ដនសាហុង ព្រោះវាមិនកាត់ផ្តាច់ទំនាក់ទំនងប្រព័ន្ធអេកូឡូស៊ីទេ ដោយដីល្បាប់អាចហូរទៅទន្លេផ្នែកខាងក្រោមបាន ហើយត្រីក៏អាចធ្វើចរាចរណ៍បាន។ ម្យ៉ាងទៀត វាមិនក៏តម្រូវឱ្យប្រជាសហគមន៍រុះរើទៅតាំងទីលំនៅថ្មីដែរ។ ទំនប់វារីអគ្គិសនីដនសាហុង និងគម្រោងថាកូមានកម្រិតទឹកតិចតួចដូចគ្នា ព្រោះវាមានទឹកគ្រប់គ្រាន់ល្មមតែនៅក្នុងតំបន់សម្រាប់សាងសង់មួយនេះ ឬមួយនោះ។ ទោះបីជាមានជម្រើសដែលបង្កការខូចខាតតិចជាងក្តី ក៏រដ្ឋាភិបាលប្រទេសឡាវបានសម្រេចចិត្តកំណត់យកទំនប់ដនសាហុងជាអាទិភាព ដែលអាចចំណាយយ៉ាងច្រើនសម្បើមចំពោះ ទន្លេមេគង្គ ប្រជាជនរបស់ខ្លួន និងកិច្ចសហប្រតិបត្តិការក្នុងតំបន់។

ជិតមួយទសវត្សរ៍មកហើយ បណ្តាសហគមន៍ទន្លេមេគង្គបាននិយាយជំទាស់នឹងផែនការសាងសង់ទំនប់ដនសាហុងតាមរយៈការតវ៉ាជាសាធារណៈ ការដាក់ញត្តិជាអន្តរជាតិ និងសិក្ខាសាលាផ្សេងៗ។ នៅខែតុលា ឆ្នាំ ២០១៤ សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិបានដាក់ពាក្យបណ្តឹងទៅគណកម្មាធិការសិទ្ធិមនុស្ស ប្រទេសម៉ាឡេស៊ី (SUHAKAM) ក្នុងនាមសហគមន៍នៅក្នុងប្រទេសកម្ពុជា និងប្រទេសថៃ ដែលមានផលប៉ះពាល់ដោយទំនប់ដនសាហុង។ ពាក្យបណ្តឹងនោះស្នើឱ្យគណកម្មការសិទ្ធិមនុស្ស SUHAKAM ស៊ើបអង្កេតផលប៉ះពាល់សង្គមនិងសេដ្ឋកិច្ច ដោយសារទំនប់ដនសាហុង ក្នុងនាមបណ្តាសហគមន៍នៅក្នុងប្រទេសទាំងពីរនេះ និងសុំឲ្យគណកម្មការនេះធានាថា ក្រុមហ៊ុន Mega First Corporation Berhad ប្រតិបត្តិតាមលិខិតបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ក្នុងនោះរួមមានកាតព្វកិច្ចខិតខំប្រឹងប្រែងជាមួយនិងផ្តល់ព័ត៌មានដល់បណ្តាសហគមន៍ដែលរងផលប៉ះពាល់។

ទោះបីជាមានការ ជំទាស់ដែលមានភស្តុតាងយ៉ាងច្បាស់ពីប្រជាជនតំបន់ទន្លេមេគង្គ និងមានការខ្វែងគំនិតថ្នាក់តំបន់កំពុងតែកើតឡើងរវាងរដ្ឋាភិបាលតំបន់ទន្លេមេគង្គទាំងបួនក្តី ក៏ផែនការសាងសង់ទំនប់ដនសាហុងបានជំរុញដំណើរការទៅមុខយ៉ាងលឿន ដោយប្រឡែងលេងនឹងអនាគតនៃទន្លេមេគង្គ និងប្រជាជននៅតាមតំបន់ទន្លេមេគង្គ និងជំរុញកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ឲ្យដល់ស្ថានភាពនៃការដួលរលំ។

## ទំនប់ដនសាហុងពុំមានការពន្យល់ហេតុផលច្បាស់លាស់

ទំនប់វារីអគ្គិសនីដនសាហុងពុំមានការពន្យល់ហេតុផលច្បាស់លាស់សម្រាប់អគ្គិសនីកម្លាំងតែ 260 MW, ក្រុមហ៊ុនអភិវឌ្ឍន៍មានផែនការ កែប្រែផ្នែកសំខាន់បំផុតមួយនៃទន្លេមេគង្គដោយមិនអាចវិលទៅរកលក្ខណៈដើមវិញបាន ដែលបង្កឲ្យមានគ្រោះថ្នាក់ដល់ចរាចរណ៍ត្រី ដោយមានផលវិបាកធ្ងន់ធ្ងរ និងមិនអាចស្តារវិញបានសម្រាប់ប្រជាជននៅទូទាំងអាងទន្លេមេគង្គ។ ដោយប្រឈមស្ថានភាពគ្រោះថ្នាក់ច្រើនបែបនេះ វាជារឿងសំខាន់ដែលការធ្វើសេចក្តីសម្រេចចិត្តត្រូវផ្អែកលើការសិក្សាល្អិតល្អន់ និងលើកិច្ចសហប្រតិបត្តិការ និងពិគ្រោះយោបល់ប្រកបដោយអត្ថន័យ។ ច្បាស់ណាស់ថា គេត្រូវការពេលវេលាច្រើនដើម្បីបញ្ចប់ ការសិក្សាជាមូលដ្ឋានដែលកំពុងប្រព្រឹត្តទៅនៅការដ្ឋានទំនប់វារីអគ្គិសនី បញ្ចប់របាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថានឆ្លងដែន ព្រមទាំងការសិក្សាយ៉ាងល្អិតល្អន់អំពីអាងទន្លេ ដែលកំពុងដំណើរការដើម្បីជាមូលដ្ឋានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តដែលមានព័ត៌មានគ្រប់ជ្រុងជ្រោយ។ បណ្តាក្រុមហ៊ុនដែលពាក់ព័ន្ធ ត្រូវតែបង្ហាញថា វិធានការកាត់បន្ថយផលប៉ះពាល់ដែលបានស្នើឡើងរបស់គម្រោងនេះ អាចធានាបាននូវនិរន្តភាពយូរអង្វែងរបស់ទន្លេមេគង្គ។

**JOIN US!**

សម្រាប់ ព័ត៌មានបន្ថែម សូមចូលទៅអានតាមអាសយដ្ឋាននេះ៖ http://www.internationalrivers.org/node/2334